**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៣៚៚

# កិច្ចព្រមព្រៀងការព្យួរកិច្ចសន្យាការងារ

ថ្ងៃចន្ទ ទី១៣ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង១៤:០០នាទីនៅក្នុងរោងចក្រ ហ៊ីង ស៊ីង ហ្គាមិន (ខេមបូឌា) ឯ.ក អាស័យដ្ឋាន ផ្លូវជាតិលេខ០១ អគារទី០៦ ភូមិព្រែកត្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ប្រទេសកម្ពុជា។ បានបើកកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងក្រុមហ៊ុន និងប្រធានក្រុម ព្រមទាំងតំណាងកម្មករនិយោជិតទាំងអស់។

## ១. សមាសភាពអ្នកចូលរួម

### ក. ភាគីតំណាងអោយក្រុមហ៊ុន

-លោកស្រី GONG QINXIAN (ប្រធានរោងចក្រ)

-លោក ប៊ុល រិទ្ធី (ប្រធានផ្នែករដ្ឋបាល)

### ខ. ភាគីតំណាងសហជីពនិងតំណាងកម្មករនិយោជិត

១.អ៊ិន ភានី ២.ហ៊ាន សុខា ៣.កៅ ស្រស់ ៤.ទូច វណ្ណនី ៥. ទូច ពៅមាស

៦. ធន់ ណារី ៧. គង់ សឿន ៨. ភា ភីមងារ ៩. សួន ភក្តី ១០. សឿន រត្ន័

១១. គុច សំអាត ១២. ជុំយ ធារិទ្ធ ១៣. វាន្នី សុភា ១៤. យ៉ាន សារី

## ២.ខ្លឹមសារអង្គប្រជុំ

សមាជិកអង្គប្រជុំទាំងមូលបានលើកឡើងអំពីបញ្ហាការព្យួរការងារនៅក្នុងរោងចក្រក្នុងរយៈពេល ០១ខែដោយចាប់ពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ ដោយពុំសូវមានការបញ្ជាទិញ។

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្ម័គ្រចិត្តដោះស្រាយដោយផ្តល់ឲ្យភាគីនីមួយៗមានលទ្ធភាពទទួលយកបាន និងបង្កលក្ខណៈដោះស្រាយតាមស្ថានភាពជាក់ស្តែងដោយទាំងតំណាងរោងចក្រ ក៏ដូចជាផ្នែកតំណាងកម្មករនិយោជិតបានព្រមព្រៀងគ្នាតាមវិធីដោះស្រាយដូចខាងក្រោមះ

១.រោងចក្របានឯកភាពផ្តល់ជូនប្រាក់ឈ្នួលកម្មករនិយោជិតចំនួន៣០ដុល្លាក្នុង១ខែកំឡុងពេលព្យួរការងារ។

Scanned with CamScanner

២.តំណាងរោងចក្រ ឯកភាពតាមសំណើររបស់តំណាងកម្មករ សហជីពមូលដ្ឋាន និងប្រធានក្រុមទាំងអស់ហើយនៅពេលក្រោយភាគីកម្មករនិយោជិតឯកភាពត្រូវធ្វើតាមនិតិវិធីនៃការចរចានិងគោរពតាមនិតិវិធីច្បាប់។

## ៣.លទ្ធផលអង្គប្រជុំ

ជាលទ្ធផល នៃការពិភាក្សាភាគី ទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

១-រោងចក្រចាប់ផ្តើមព្យួរការងារ កម្មករនិយោជិត ចំនួន២០៦ នាក់។ ចាប់ផ្តើមពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ ។

២. រោងចក្រផ្តល់ប្រាក់ឈ្នួលគោល៣០ដុល្លាក្នុង១ខែក្នុងពេលព្យួរការងារ ។

៣.ករណីដែលរោងចក្រមានការងារធ្វើក្នុងកំឡុងពេលព្យួររោងចក្រអនុញ្ញាតិអោយកម្មករនិយោជិតចូលធ្វើការមុនពេលកំណត់។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១៥:00 នាទីនាថ្ងៃដដែល។ ក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខាក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

### ក.ភាគីតំណាងសហជីព និងតំណាងកម្មករនិយោជិត

| | | | | |
|---|---|---|---|---|
| ១.អ៊ិន ភានី | ២.ហ៊ាន សុខា | ៣.កៅ ស្រស់ | ៤.ទូច វណ្ណនី | ៥. ទូច ពៅមាស |
| ៦. ធន់ ណាវី | ៧. គង់ សៀន | ៨. ភា គីមដាវ | ៩. សួន ភក្តី | ១០. សៀន រត្ន័ |
| ១១. គុច សំអាត | ១២. ង៉ុយ ធារិទ្ធ | ១៣. ភន្នី សុភា | ១៤. យ៉ាន សារី | |

ហត្ថលេខា និងត្រា

**ប្រធានរោងចក្រ**

Scanned with CamScanner